ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ព្រះយេស៊ូជាគ្រូបង្រៀនដ៏អស្ចារ្យ



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus
Alastair Paterson

កែសម្រួលដោយ៖ E. Frischbutter; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។



ព្រះយេស៊ូ ជាគ្រូ
បង្រៀនដ៏ល្អបំផុត។ មហា
ជនជាច្រើនបានស្តាប់សេចក្តីបង្រៀនរបស់ព្រះ
អង្គ។ ព្រះយេស៊ូបានបង្រៀនអំពី សេចក្តីមេត្តាករុណា
និងសេចក្តីសប្បុរស។ ទោះបីអ្នកផ្សេងទៀតអាចស្អប់
ឬធ្វើបាបពួកគេក៏ដោយ ក៏ប៉ុន្តែព្រះជាម្ចាស់
យកព្រះហឫទ័យទុកដាក់ចំពោះពួកគេ។



ព្រះយេស៊ូបានបង្រៀនមេ
រៀនជាច្រើន។ ព្រះអង្គមាន
បន្ទូលថា៖ “ប្រជារាស្ត្ររបស់
ព្រះជាម្ចាស់ ត្រូវធ្វើជាពន្លឺនៃ
ពិភពលោក ដូចជាចង្កៀង
ដែលបំភ្លឺនៅក្នុងផ្ទះ”។ តើវា
ផ្លាស់ប្ដូរយ៉ាងណាទៅ ពេល
មានពន្លឺបំភ្លឺនៅក្នុងទីងងឹត
សូន្យសុងនោះ!

មនុស្សដែលព្រះយេស៊ូមានបន្ទូលទៅកាន់នោះ គេជឿថា៖ “ភ្នែកសង
ដោយភ្នែក ធ្មេញសងដោយធ្មេញ”។ ប៉ុន្តែព្រះយេស៊ូបានបង្រៀនពីសេ
ចក្តីសប្បុរស ការអត់លើកលែងទោស និងការស្រឡាញ់ចំពោះខ្មាំង
សត្រូវវិញ។




នៅថ្ងៃសប្ប័ថ មានមនុស្សជាច្រើនបានសម្តែង
ធ្វើដូចខ្លួនជាមនុស្សបរិសុទ្ធ។ នៅពេលពួកគេ
ដាក់ទានដល់ជនណាម្នាក់ គេមានអ្នកផ្លុំត្រែដ
ប្រកាសឲ្យមនុស្សផ្សេងបានឃើញការដាក់
ទានរបស់គេ។ ព្រះយេស៊ូមានបន្ទូលថា៖’’ចូរ
ដាក់ទៀនដោយស្ងាត់កំបាំង
នោះព្រះជាម្ចាស់នឹងប្រទានពរ
ដល់អ្នក’’។

ព្រះយេស៊ូក៏បានបង្រៀនអំពីការអធិស្ឋានដូចគ្នាដែរ។ មនុស្សខ្លះគេ អធិស្ឋាននៅផ្លូវកែង ដើម្បីឲ្យមនុស្សឆ្លងកាត់តាមនោះ បានឃើញ និងព្ទពួកគេអធិស្ឋាន។ តាពិតទៅ ពួកដូច្នោះ បង្ហាញថា គេមិនបានខ្វល់ខ្វាយពីព្រះជាម្ចាស់ទេ។ ពួកខ្វល់ខ្វាយអំពីអ្វីដែលមនុស្សគិតអំពីពួកគេតែប៉ុណ្ណោះ។ ព្រះយេស៊ូហៅពួកគេថា៖” ជាមនុស្សលាក់ពុត”។



ព្រះយេស៊ូបានពន្យល់អំពីសេចក្តីបង្រៀនរបស់ព្រះអង្គ ដោយប្រើប្រាស់ធម្មជាតិ។ ព្រះអង្គចង្អុលទៅបក្សាបក្សី ហើយមានព្រះបន្ទូលថា “ព្រះបិតាដែលនៅឋានសួគ៌ ព្រះអង្គផ្តត់ផ្គង់ពួកវានូវអាហារជាបរិបូរ ដូច្នេះកុំខ្វល់ខ្វាយឡើយ ព្រះជាម្ចាស់នឹងផ្គត់ផ្គង់អ្នករាល់គ្នាលើសជាងបក្សាបក្សីទាំងនោះផង”។



ព្រះយេស៊ូមានព្រះបន្ទូលថា ៖ “សូម្បីតែព្រះបាទសាឡូម៉ូន កាលពីជំនាន់ដែលទ្រង់មានសិរីរុងរឿងដ៏ប្រសើរបំផុតនោះក៏ដោយ ក៏ទ្រង់គ្មានព្រះភូសាល្អស្មើនឹងផ្កាមួយទងនេះផង។ប្រសិនបើព្រះជាម្ចាស់ផ្តល់សំរស់អោយផ្កាដែលរីកនៅតាមវាលថ្ងៃនេះ តែថ្ងៃស្អែកត្រូវគេដុតចោលយ៉ាងហ្នឹងទៅហើយ តើព្រះអង្គនឹងទំនុកបម្រុងអ្នករាល់គ្នាលើសនេះយ៉ាងណាទៅ
ទៀត?”។



ព្រះយេស៊ូបានកំពុងបង្រៀនមនុស្សឲ្យចេះទុកចិត្តលើព្រះជាម្ចាស់ ដែលព្រះអង្គជា អ្នកផ្គត់ផ្គង់ និង បំពេញសេចក្តីត្រូវរបស់យើង។



ព្រះយេស៊ូមានព្រះបន្ទូលថា៖ “បើអ្នកថ្កោលទោសបងប្អូនរបស់អ្នក គឺប្រៀបបាននឹងការព្យាយាមយកល្អងធូលីចេញពីភ្នែករបស់គេ ស្រប ពេលដែលអ្នកមានធ្នឹមនៅក្នុងភ្នែករបស់អ្នក”។ ប្រហែលជាមនុស្សបានសើចចម្អកចំពោះការបង្រៀននេះ។ ប៉ុន្តែពួកគេត្រូវពិចារណាពីអត្ថន័យនៃព្រះបន្ទូលរបស់ព្រះអង្គផងដែរ។



ព្រះយេស៊ូមានបន្ទូលថា មនុស្សលោកត្រូវសុំជំនួយពី
ព្រះជាម្ចាស់។ តើអ្នកគិតថាឪពុកទាំងឡាយនឹងឲ្យដុំថ្ម
ពេលកូនសុំនំប៉័ងមែនទេ? ទេ! គឺឪពុកទាំងនោះ នឹងឲ្យ
នំប៉័ងទៅកូនមិនខានឡើយ។ ព្រះជាម្ចាស់នឹងប្រទាន
ដល់អ្នកណាដែលទូលសុំព្រះអង្គផងដែរ។



ព្រះយេស៊ូ ជាគ្រូបង្រៀនដ៏អស្ចារ្យ បានដាស់តឿនអំពីគ្រូបង្រៀនក្លែងក្លាយ។ ព្រះយេស៊ូមានបន្ទូលថា៖ “ពួកគេពាក់រោមចៀម តែខាងក្នុងរបស់គេគឺជាសត្វចចក”។ គេអាចស្គាល់គ្រូក្លែងក្លាយទាំងនោះបានតាមរយៈអំពើដែលគេប្រព្រឹត្ត។



ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់គេជាសាច់រឿងមួយ ក្នុងរឿងនោះព្រះយេស៊ូបានបង្ហាញថា អស់អ្នកដែលស្តាប់ហើយធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ គឺប្រៀបបាននឹងមនុស្សឈ្លាសវៃដែលបានសង់ផ្ទះរបស់ខ្លួននៅលើថ្មដ៏រឹងមាំ។ នៅពេលព្យុះបោកបក់មក ផ្ទះនោះគឺនៅរឹងមាំដដែល។



រីឯមនុស្សល្ងង់វិញ បានសង់ផ្ទះរបស់ខ្លួនដោយចាក់គ្រឹះនៅលើដីខ្សាច់។ ពេលមានព្យុះបោកបក់មក ផ្ទះនោះក៏ដួលរលំខ្ទេចខ្ទីអស់ ព្រោះវាគ្មានគ្រឹះរឹងមាំ។ ព្រះយេស៊ូមានបន្ទូលថា មនុស្សដែលស្ដាប់ហើយមិនធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ ប្រៀបបាននឹងមនុស្សដែលសង់ផ្ទះលើដីខ្សាច់អញ្ចឹងដែរ។



មនុស្សជាច្រើន មានការភ្ញាក់ផ្អើលនឹងសេចក្តី
បង្រៀនរបស់ព្រះយេស៊ូជាខ្លាំង។ ពួកគេមិនដែលស្តា
ប់សេចក្តីបង្រៀនបែបនេះពីមុនមកទេ។ ឥឡូវពួកគេ
បានដឹងហើយថា គ្រាន់តែចេះព្រះបន្ទូលព្រះ មិន
គ្រប់គ្រាន់នោះទេ។ ពួកគេត្រូវតែធ្វើតាមបន្ទូលផង
ទើបគ្រប់គ្រាន់ដែរ។



ព្រះយេស៊ូជាគ្រូបង្រៀនដ៏អស្ចារ្យ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់,

អាចរកឃើញនៅក្នុងព្រះគម្ពីរ

ម៉ាថាយ ៥-៧ លូកា ៦

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម៉្លេះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឪព្រះយេស៊ូទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ! យូហាន ៣:១៦